# ព្រះរាជក្រឹត្យ

នស/រកត/០៥១៤/៥៨៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៧៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការកំណត់ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ ក្នុងអាណត្តិទី២:

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | ឯកឧត្តម **ឃឹម សុខុម** | ១០-០២-១៩៥៥ | ជាប្រធានក្រុមប្រឹក្សាខេត្ត |
| ២- | ឯកឧត្តម **ហួត ថន** | ០៩-០១-១៩៤៩ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★
ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៣- | ឯកឧត្តម **ម៉ុក ស៊ិន** | ២០-០៥-១៩៣៩ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ៤- | ឯកឧត្តម **អ៊ិន យុន** | ០៤-០១-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ៥- | លោកជំទាវ **កែវ សុខុម** | ១៥-០៤-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ៦- | ឯកឧត្តម **ជួន ខឡូនា** | ០៧-០៤-១៩៨៣ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ៧- | លោកជំទាវ **ជិន សំនៀង** | ២១-១០-១៩៨១ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ៨- | ឯកឧត្តម **សុខ យ៉ាន** | ១៣-០៥-១៩៤៧ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ៩- | ឯកឧត្តម **ជាស ឌីម** | ១០-១១-១៩៤៨ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ១០- | ឯកឧត្តម **ម៉ែន គឿន** | ១៥-០១-១៩៤៨ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ១១- | ឯកឧត្តម **ញឹម សុខ** | ១៥-០៥-១៩៥១ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ១២- | ឯកឧត្តម **សៀង ទូច** | ០៩-០៩-១៩៦២ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ១៣- | ឯកឧត្តម **ទៀង សៀន** | ១៨-០៧-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ១៤- | ឯកឧត្តម **ប៉ុល សារឿន** | ០៦-០៧-១៩៦៤ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ១៥- | ឯកឧត្តម **សឹទ្ធ ស៊ុន** | ១៧-០៥-១៩៤៧ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ១៦- | ឯកឧត្តម **ប្រាក់ ណុប** | ១៥-០៣-១៩៥១ | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ១៧- | ឯកឧត្តម **ទួន មីន** | ០៤-០៤-១៩៦៤ | ជាសមាជិកក្រុមប្រឹក្សាខេត្ត។ |

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣០ឧ. ១៤០៥. ២៥១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៤

លេខ: ៦៤៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**